ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែកក្កដា ឆ្នាំ២០១៣

## I- សភាពការណ៍រួម

ក្នុងខែកក្កដា ឆ្នាំ២០១៣នេះ ស្ថានភាពអាកាសធាតុទទួលឥទ្ធិពលពីជ្រលងសម្ពាធទាប ផ្ទៃមេឃមានពពកពីតិចទៅច្រើន ខ្យល់បក់ពីទិសនិរតីនិងមានភ្លៀងធ្លាក់តិចតួចនៅតាមតំបន់មួយចំនួននៃរាជធានី ខេត្ត។ ទោះបីទឹកភ្លៀងមិនទាន់អំណោយផលល្អប្រសើរគ្រប់តំបន់យ៉ាងណាក៏ដោយ ក៏ប្រជាកសិករទូទាំងប្រទេសបាននិងកំពុងខិតខំជំរុញការងារបង្កបង្កើនផលគ្រប់មុខដំណាំ ជាពិសេសការងារបង្កបង្កើនផលស្រូវមានជាអាទិ៍ ការរៀបចំដី ភ្ជួររាស់ សាប-ព្រោះ ដក-ស្ទូង ស្មើនឹង៦៩,៤១ភាគរយ នៃផែនការដាំដុះ ២.៣៩៩.៦៣៧ហិកតា។

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ៗ) ផ្នែកដាំដុះ

#### ១.១ ដំណាំស្រូវរដូវវស្សាឆ្នាំ២០១៣

១.១.១ ដំណាំស្រូវ

-ផ្ទៃដីភ្ជួររាស់សរុបចំនួន២.៤០៩.២៦៣ហិកតា (ក្នុងនោះគោ-ក្របីចំនួន៦៥២.១១៣ហិកតា)លើសឆ្នាំមុន ៧៧.៩៣៩ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំ ២១២.១៥៦ហិកតា

-ផ្ទៃដីសាបសរុបចំនួន១៣៦.៨៥៥ហិកតា តិចជាងឆ្នាំមុន១៧.៧៣១ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំ ៤៣.២២៤ហិកតា

-ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន១.៦៦៥.៥១៨ហិកតា ស្មើនឹង៦៩,៤១% នៃផែនការ២.៣៩៩.៦៣៧ហិកតា លើសឆ្នាំមុន៩.៩០០ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំ២១៥.៨៩៨ហិកតា

- ស្រូវស្រាលចំនួន ៤៥៣.០៤៤ហិកតា (ក្នុងនោះស្រូវបង្កើនរដូវចំនួន២១៥.៧៩៣ហិកតា) តិចជាងឆ្នាំមុន ៣៣.០១៦ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំ ៩៣.៩៥៨ហិកតា
- ស្រូវកណ្តាលចំនួន ៦៨៥.៧១៦ហិកតា លើសឆ្នាំមុន ១០.៧២៣ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំ ៩០.៩៣៦ហិកតា
- ស្រូវធ្ងន់ចំនួន ៣៩៨.៦០៩ហិកតា លើសឆ្នាំមុន ១៥.៣០៩ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំ ៤៥.៣៨៤ហិកតា
- ស្រូវចម្ការចំនួន ៤៩.៣៧៧ហិកតា លើសឆ្នាំមុន ៤.៨២១ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំ ២.១០៥ហិកតា



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

• ស្រូវឡើងទឹកចំនួន ៧៨.៧៧២ហិកតា លើសឆ្នាំមុន ១២.០៦៣ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំ ១៦.៤៨៥ហិកតា។

-ការងារប្រមូលផលស្រូវស្រាលដើមរដូវក្នុងខែកក្កដានេះសម្រេចបានលើផ្ទៃដីចំនួន ៦២.៤០៧ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន ២៣៦.៩៣៧តោន និងទិន្នផលជាមធ្យមចំនួន ៣,៧៩០តោនក្នុងមួយហិកតា។

១.១.២ ដំណាំរួមផ្សំ

ផ្ទៃដីសម្រេចបានចំនួន ៥៧៤.៤៥៦ហិកតា ស្មើនឹង ១១១,០៦ភាគរយ នៃផែនការសរុប ៥១៧.២៦០ហិកតា លើសឆ្នាំមុន ៨០.១០២ហិកតា ក្នុងនោះមាន៖

-ផ្ទៃដីដាំពោតចំនួន១២៩.៦៣៦ហិកតា លើសឆ្នាំមុន៩.៣៦៤ហិកតា ក្នុងនោះផ្ទៃដីដាំពោតក្រហមមាន ១១២.៨០១ហិកតា

-ផ្ទៃដីដំឡូងឈើចំនួន ៣៧៣.៩៥១ហិកតា លើសឆ្នាំមុន ៧១.១៣៨ហិកតា

-ផ្ទៃដីដំឡូងជ្វាចំនួន ៣.៧២៧ហិកតា តិចជាងឆ្នាំមុន ១៨៦ហិកតា

-ផ្ទៃដីបន្លែគ្រប់មុខចំនួន ២៤.៨១០ហិកតា លើសឆ្នាំមុន ៨៣ហិកតា

-ផ្ទៃដីសណ្ដែកបាយចំនួន ៤២.៣៣២ហិកតា តិចជាងឆ្នាំមុន ២៩៧ហិកតា ។

១.១.៣ ដំណាំឧស្សាហកម្ម

ផ្ទៃដីសម្រេចបាន ១០០.៦៩៧ហិកតា ស្មើនឹង ៦៥,២១ភាគរយ នៃផែនការសរុប ១៥៤.៤២៩ហិកតា លើសឆ្នាំមុន ៩.១០៥ហិកតា ក្នុងនោះមាន៖

-ផ្ទៃដីសណ្ដែកដីចំនួន ១៥.៦៥០ហិកតា លើសឆ្នាំមុន ២.២៧៥ហិកតា

-ផ្ទៃដីសណ្ដែកសៀងចំនួន ៣៤.១០៣ហិកតា លើសឆ្នាំមុន ៥.៧៦៥ហិកតា

-ផ្ទៃដីល្ងចំនួន ៣៣.៤៩៩ហិកតា តិចជាងឆ្នាំមុន ៣.៣៣៥ហិកតា

-ផ្ទៃដីអំពៅចំនួន ១៧.១៤៧ហិកតា តិចជាងឆ្នាំមុន ៤៧៨ហិកតា

-ផ្ទៃដីក្រចៅចំនួន ២១៦ហិកតា លើសឆ្នាំមុន ៣៦ហិកតា

-ផ្ទៃដីថ្នាំជក់ចំនួន ៨២ហិកតា លើសឆ្នាំមុន ៤២ហិកតា។

## ២ ផ្នែកព្រៃឈើ

### ២.១ ការងារចំណូលព្រៃឈើ

-ចំណូលពីផលព្រៃឈើចូលថវិកាជាតិសរុបចំនួន៣៤.៦៦៦.៨៥១.៧០៧រៀល ដែលក្នុងនោះបានមកពីចំណូលថ្លៃសួយសារផល អនុផលព្រៃឈើចំនួន៨.២៥៥.៥៩៣.៥២០រៀល ផលទុនពីការលក់-ជួលទ្រព្យសម្បត្តិនិងសេវាចំនួន ២៩.៥៨៦.៩៥៦.៩២១រៀល និងចំណូលបានពីការផាកពិន័យឈើដែលបានមកពីការបង្ក្រាបបទល្មើសចំនួន ៥.០៧១.០៩៤.៧៨៦រៀល។

### ២.២ ការងារព្រៃឈើនិងសហគមន៍ព្រៃឈើ

-ផ្ញើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើជូនក្រុមហ៊ុនចំនួន០២

-ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ចេញពីព្រៃគុបផ្តល់ផលក្រៅពីព្រៃសម្បទាន៖ ឈើហ៊ុបមូលសរុបចំនួន ៥.៣០០,៩០២ម៣ ឈើអារចំនួន ៣៥៦,៤៣៨ម៣ កូនឈើចំនួន ៥.៦៤០ដើម អុសចំនួន ៦០០ស្ទែរ និងគល់ផ្ចង់ចំនួន ៤.១២៥គីឡូក្រាម។

### ២.៣ ការងារអភិរក្សសត្វព្រៃ

-ជំរឿនសត្វស្លាបដែលមាននៅក្នុងតំបន់អភិរក្សបឹងព្រែកល្ពៅចំនួន៧៦៨ក្បាល នៅក្នុងតំបន់អភិរក្សអន្លង់ព្រីងចំនួន

៩១៤ក្បាល នៅក្នុងតំបន់អភិរក្សអាងត្រពាំងថ្មចំនួន ៤២.០៧០ក្បាល និងនៅក្នុងតំបន់អភិរក្សសត្វខ្សឹបកំពង់ធំ-សៀមរាប ចំនួន៧០.៥១៦ក្បាល

-រកឃើញនិងការពារសម្បុកពងកូនសត្វក្រៀលចំនួន០២សម្បុកនៅព្រៃការពារព្រះវិហារ សម្បុកត្រយ៉ងយក្សចំនួន ០៦សម្បុកនៅព្រៃការពារព្រះវិហារនិងខេត្តក្រចេះ និងសត្វត្រដក់តូចចំនួន០២សម្បុក នៅព្រៃការពារព្រះវិហារ

-រៀបចំអាហារដ្ឋានត្មាតនៅតំបន់វាលព្រួសនៃព្រៃការពារព្រះវិហារចំនួន០១លើកសរុបចំនួន៤០ក្បាល

-ចុះរាប់សត្វត្រយ៉ងចង្កិកសក្នុងខេត្តក្រចេះសរុបចំនួន១៤៨ក្បាល

-ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សាសរុបចាប់ពីដើមឆ្នាំ សត្វចំណូលថ្មីចំនួន៣៤៣ក្បាល សត្វកើតថ្មីចំនួន៥០ក្បាល សត្វដោះលែងចំនួន១៧៨ក្បាល សត្វស្លាប់ចំនួន៧៨ក្បាល ព្យាបាលសត្វចំនួន១៧១ក្បាល យកសំណាកទៅពិសោធន៍ចំនួន២៥៦ក្បាល ធ្វើឱ្យសន្លប់ចំនួន១១៤ក្បាល ទម្លាក់សត្វល្អិតចំនួន៥០៥ក្បាល វះកាត់សាកសពសត្វចំនួន២៩ក្បាល ដាក់លេខកូដចំនួន១៣ក្បាល ចាក់វ៉ាក់សាំងចំនួន៤១១ក្បាល ជួសជុលផ្លូវចំនួន១៦៨.១៧២ម$^2$ និងថ្លារអនាម័យព្រៃ១៥២.៩៦៤ម$^2$ សាងសង់ទ្រុងសត្វនិងអគារផ្សេងៗចំនួន៣.៥៦១ម$^2$ សាងសង់របងហ៊ុមព័ទ្ធនិងទ្រុងសត្វថ្មីលើដីចំនួន១៣.២២៣ម$^2$ សាងសង់សំណង់ផ្សេងៗចំនួន៩៧៥ម$^2$ ដាំកូនឈើចំនួន ២៥៤ដើម បណ្តុះផ្កាលម្អ(ផ្កាក្រដាស)ចំនួន៣.២០៨ដើម និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន៨.៨៥៤នាក់

-ក្រុមហ៊ុនចំនួន ០៧ កំពុងចិញ្ចឹមសត្វក្ដាមចំនួន៧៦.៤៥០ក្បាល។

**២.៤ ការងារដាំដើមឈើ**

-ស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើចំនួន០៥របស់រដ្ឋបាលព្រៃឈើ បណ្តុះកូនឈើគ្រញូងបានចំនួន៥៩០.០០០ដើម (គ្រប់ផែនការ) ឈូសឆាយដីព្រៃបានចំនួន១១៥ហិកតាលើផែនការចំនួន៤០០ហិកតា ដាំកូនគ្រញូងបានចំនួន៧០ហិកតា និងស្ថានីយដាំឈើចំនួន១០ លើផ្ទៃដីចំនួន៣.៨៦៨ហិកតា ត្រូវធ្វើការថែទាំនិងការពារជាប្រចាំ។ ដោយឡែកចម្ការឆ្នាំទី១ ឬឆ្នាំទី២ ដែលទទួលរងការខូចខាតដោយភ្លើងឆេះកំពុងរៀបចំដាំបំពេញផែនការឡើងវិញនៅតាមស្ថានីយដាំឈើមានក ភ្នំគូលេន ក្បាលឆាយ និងក្រសាំង

-ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចបានឈូសឆាយដីព្រៃចំនួន ២.១០១ហិកតា និងដាំកូនឈើនិងកូនកៅស៊ូចំនួន ១.០៥០ហិកតា

-ថ្នាលបណ្តុះកូនឈើរបស់រដ្ឋបាលព្រៃឈើអនុវត្ត÷ កូនឈើសល់ស្តុកក្នុងឆ្នាំ២០១២ចំនួន៧៥៣.១៩៧ដើម កូនឈើបណ្តុះក្នុងឆ្នាំ២០១៣សរុបចំនួន៣៩២.៣៤៤ដើម និងចែកចាយកូនឈើក្នុងឆ្នាំ២០១៣សរុបចំនួន៣៧.៤៩៣ដើម

-សួនអាពាហ៍ពិពាហ៍១ទីតាំងមានទំហំដី៥៣ហិកតា ស្ថិតនៅភូមិ១ ឃុំឡាមិញ ស្រុកបរកែវ ខេត្តរតនគិរី

-ពិធីបុណ្យរុក្ខទិវា ៩ កក្កដា ២០១២ ប្រារព្ធធ្វើនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើក្បាលឆាយ ដែលស្ថិតនៅក្នុងភូមិ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ដោយមានការដាំដុះប្រភេទឈើគ្រញូង គគីរ និងឈើទាលលើផ្ទៃដីចំនួន ២០ហិកតា និងមានប្រជាពលរដ្ឋចូលរួមចំនួន ៧.៥០០នាក់

-ការដាំឈើដៃគូជាមួយក្រុមហ៊ុន Think Biotech(Cambodia) Co., Ltd បានឈូសឆាយសម្អាតដីចំនួន ៣០០ហិកតា ផលិតពូជកូនឈើចំនួនចំនួន២.០០០.០០០ដើម ដាំដុះកូនឈើប្រភេទអាកាស្យាហាយប្រីតចំនួន២០ហិកតា និងសាងសង់រោងចក្រកែច្នៃឈើបានប្រមាណ៥០%

-ដំណាំកសិរុក្ខកម្ម មានឡូត៍ស្រាវជ្រាវប្រព័ន្ធកសិរុក្ខកម្មទំហំ ៥ហិកតា ដែលមានទីតាំងនៅខេត្តកំពង់ធំ កំពុងដំណើរការឈូសឆាយបាន០៥ហិកតា។

**២.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម**

**២.៥.១ ការងារពាណិជ្ជកម្មនាំចេញ នាំចូល**

-ពិនិត្យឯកសារស្នើសុំពាក់ព័ន្ធនឹងការនាំចេញនាំចូលចំនួន ០២ក្រុមហ៊ុន

-ផ្តល់អាជ្ញាប័ណ្ណនាំចេញឈើកែច្នៃគ្រប់ប្រភេទជូនក្រុមហ៊ុន អិម ឌី អេស អាហ៍រណ នីហ៍រណ ដែលមានបរិមាណឈើចំនួន២.០៩០,៩៧៥ម៣។

### ២.៥.២ ការងារឧស្សាហកម្ម

-ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចេញជូនក្រុមហ៊ុនចំនួន០២។

## ២.៦ ការងារនីតិកម្មនិងវិវាទ

-រៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើតស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើចំនួន១២ស្ថានីយ គឺស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើអង្គាញ់ ស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើស្រែឈ្ងោយ ស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើយុនរាម ស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើផែប ស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើកូនក្រៀល ស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើត្រពាំងតាវ ស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើកូនខ្លែង ស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើរមនា ស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើសែនមនោរម្យ ស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើក្រយា-បឹងល្វា ស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើទឹរីង និងស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើសណ្តាន់

-បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃសរុបចំនួន ១០២ករណី

-ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើហ៊ុបមូលចម្រុះប្រភេទចំនួន៣៩,៤០៩ម៣ ឈើអារចំនួន៨៨,៣៥៦ម៣ ឈើក្រាក់គ្រញូងចំនួន១៤,១៩០ម៣ កូនឈើចំនួន៦០៣ដើម ឈើជន្លង់ម្រេចចំនួន៤២៩ដើម សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន៦៣,៧០គ.ក្រនិង១៤៩ក្បាល រថយន្តចំនួន៣៧គ្រឿង ម៉ូតូចំនួន០៨គ្រឿង ទូក-កាណូតចំនួន០២គ្រឿង ម៉ាស៊ីនផ្សេងៗចំនួន០៥គ្រឿង រណារខ្សែចំនួន០១គ្រឿង រណារយន្តចំនួន០២គ្រឿង និងសម្ភារផ្សេងៗទៀតព្រមទាំងដកហូតដីព្រៃឈើចំនួន ៣០៧,១៨៧ហិកតា

-ចុះស្រង់ស្ថិតិដីព្រៃឈើដែលបានកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីវាតយកដីធ្វើកម្មសិទ្ធិចំនួន ១.៤៦២,៤៩៥ហិកតា និងដកហូតដីព្រៃដែលបានកាប់រានសរុបចំនួន១.៦៤៤,២៦០ហិកតា ។

# ៣ ផ្នែកជលផល

## ៣.១ អាជីវកម្មនេសាទ

### ៣.១.១ នេសាទទឹកសាប

-ដាយត្រីក្នុងរដូវនេសាទឆ្នាំ២០១២-២០១៣(បញ្ចប់រដូវ) សរុបបានចំនួន៨.៥០០តោន ស្មើ៨៥%នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៩១.៥០០តោន

-នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៣ *ក្នុងខែចំនួន១៥.០០០តោន* សរុបបានចំនួន១៤៥.០០០តោន ស្មើ ៤៨,៣៣% នៃផែនការ៣០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣០.០០០តោន

-នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៣ *ក្នុងខែចំនួន១០.០០០តោន* សរុបបានចំនួន៦០.០០០តោន ស្មើ៤០% នៃផែនការ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣០.០០០តោន ។

### ៣.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៣

*-ក្នុងខែចំនួន៧.០០០តោន* សរុបបានចំនួន៥៨.០០០តោន ស្មើ៦៤,៤៤%នៃផែនការ៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២.០០០តោន។

## ៣.២ វារីវប្បកម្ម

-ការចិញ្ចឹមត្រីនិងបង្គា *ក្នុងខែចំនួន៨.០០០តោន* សរុបបានចំនួន៥០.០០០តោន ស្មើ៦២,៥០%នៃផែនការ៨០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១.០០០តោន

-ការចិញ្ចឹមក្របី *ក្នុងខែចំនួន២០.០០០ក្បាល* សរុបបានចំនួន១៧០.០០០ក្បាល ស្មើ៨៥% នៃផែនការ ២០០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១០.០០០ក្បាល

-ការភ្ញាស់កូនត្រីពូជ *ក្នុងខែចំនួន១០.០០០.០០០កូន* សរុបបានចំនួន៨០.០០០.០០០កូន ស្មើ៥៣,៣៣% នៃផែនការ១៥០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៨.០០០.០០០កូន ។

**៣.៣ ការកែច្នៃផលនេសាទ**

-ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១២-២០១៣ *ក្នុងខែចំនួន៥.០០០តោន* សរុបបានចំនួន៤០.០០០តោន ស្មើ៤០% នៃផែនការ១០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣៣.០០០តោន

-ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៣ *ក្នុងខែចំនួន៣០០តោន* សរុបបានចំនួន៥.០០០តោន ស្មើ៨៣,៣៣% នៃផែនការ៦.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២០០តោន

-ការផលិតទឹកត្រី *ក្នុងខែចំនួន២.០០០.០០០លីត្រ* សរុបបានចំនួន៤០.០០០.០០០លីត្រ ស្មើ៦៦,៦៧% នៃផែនការ៦០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៣.០០០.០០០លីត្រ។

**៣.៤ ការនាំចេញផលនេសាទ**

-ផលនេសាទស្រស់ *ក្នុងខែចំនួន៥០០តោន* សរុបបានចំនួន៧.០០០តោន ស្មើ៣៥% នៃផែនការ២០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២.០០០តោន

-ផលនេសាទកែច្នៃ *ក្នុងខែចំនួន៥០០តោន* សរុបបានចំនួន៣.៥០០តោន ស្មើ៣៥% នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈគេលដូចគ្នា ថយចុះចំនួន៥០០តោន។

**៣.៥ ការការពារប្រភពធនធានជលផល**

-កំណត់ហេតុបទល្មើស សរុបចាប់ពីដើមឆ្នាំចំនួន ១.៥៥០ករណី ដែលកើតមាននៅតំបន់ទឹកសាប ១.៥០០ករណី និងតំបន់សមុទ្រ ៥០ករណី ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន ២២៥ករណី គឺតំបន់ទឹកសាប២០០ករណីនិងតំបន់សមុទ្រ២៥ករណី។ ជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព។

**៣.៦ ការប្រមូលចំណូល**

-ចំណូលពីវិស័យជលផល *ក្នុងខែចំនួន១៣២.៥២៧.៨៩៤រៀល* សរុបបានចំនួន១.៥៣៦.៩៨៤.៥៩១រៀល ស្មើ ៥២,១៥% នៃផែនការ២.៩៤៧.០០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២.០៥៩.៥៤១.៧០៩រៀល។

## ៤ ផ្នែកផលិតកម្មនិងបសុពេទ្យសាស្ត្រ

**៤.១ ការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ**

-ចាក់ថ្នាំការពារជំងឺឆ្លងលើគោ ក្របី ជំងឺសារទឹកចំនួន ៣៦១.៨៧៩ក្បាល ជំងឺអុតក្តាមចំនួន ៤៦.៤១៩ក្បាល និង ជំងឺបូសខ្យល់ចំនួន ២.១៨៧ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើសត្វជ្រូក ជំងឺសារទឹកចំនួន ១០.៣៥៤ក្បាល ជំងឺប៉េស្តចំនួន ១៥.៣៧២ក្បាល ជំងឺសាល់ម៉ូណេឡូសចំនួន ៨.០៥១ក្បាល ជំងឺអុតក្តាមចំនួន ៤៤៦ក្បាល ជំងឺអូហ្យេស្គីចំនួន ២.៩៥៤ក្បាល ជំងឺរាគកូនជ្រូកចំនួន ២.៥៤៥ក្បាល ជំងឺកញ្ជ្រិលចំនួន ៨៣ក្បាល ជំងឺជាតិដែកចំនួន ១.០៧៩ក្បាល និងជំងឺផ្លូវដង្ហើមចំនួន ៧៦ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើបក្សី ជំងឺអុតចំនួន ១៧.៣៤៤ក្បាល ជំងឺញូវកាសចំនួន ៤៣.៩៣០ក្បាល ជំងឺប៉េស្តទាចំនួន ១១.៧៣៧ក្បាល និងជំងឺអាសន្នរោគចំនួន ៣២.៤១៥ក្បាល។

**៤.២ ការងារវិទ្យាស្ថានជាតិស្រាវជ្រាវបសុពេទ្យសាស្ត្រ**

-ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្តាម ជំងឺសារទឹក ជំងឺបូសខ្យល់ និងជំងឺប៉េស្តជ្រូក

-រៀបចំធ្វើឱ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ

-អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺទូទៅនៅរាជធានី ខេត្ត

-ផ្នែកពិនិត្យវត្ថុវិភាគសរុបចំនួន ២៦៥សំណាក

-ផ្នែកសរីរោគសាស្ត្រសរុបចំនួន ០៦ក្បាល ។

**៤.៣ ការអនុវត្តច្បាប់បសុពេទ្យ**

-ទទួលទូរស័ព្ទហៅចូលសរុបចំនួន ០៩ករណី មកពីតាមបណ្តារាជធានី ខេត្ត សាកសួរពីរោគសញ្ញា វិធានការការពារ ការធ្វើជីវសុវត្ថិភាព និងរាយការណ៍ពីបក្សីឈឺ ងាប់

-ចុះអង្កេតតាមដានស្រាវជ្រាវករណីសង្ស័យជំងឺផ្តាសាយបក្សីលើបក្សីនៅក្នុងភូមិបល្ល័ង្គ ឃុំកន្ទោមអក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដែលមានក្មេងប្រុសម្នាក់ឈ្មោះ តឹម ម៉េងជូ អាយុ៣ឆ្នាំ បានស្លាប់ដោយសារជំងឺផ្តាសាយបក្សីប្រភេទ H5N1

-ចុះអង្កេតតាមដានឃ្លាំមើលជំងឺផ្តាសាយបក្សីប្រភេទ A/H7N9 នៅតាមទីផ្សាររាជធានីភ្នំពេញ តាកែវ កំពង់ចាម ព្រៃវែង និងកំពត

-ធ្វើការត្រួតពិនិត្យការដឹកជញ្ជូនគោ ក្របី បានចំនួន១៦ករណី ជ្រូកចំនួន១៩ករណី និងស៊ុតចំនួន១ករណី និងធ្វើការផាកពិន័យបានចំនួន៥ករណី ជាទឹកប្រាក់ចំនួន ១៦លាន៥សែនរៀល។

-ធ្វើការទប់ស្កាត់ចលនាបក្សីនិងផលិតផលបក្សីដែលនាំចូលពីប្រទេសជិតខាង ដោយបានណែនាំប្រជាពលរដ្ឋ និងអាជីវករឲ្យយល់ដឹងពីផលវិបាកដែលបណ្តាលមកពីជំងឺផ្តាសាយបក្សី ។

**៤.៤ ការងារឡជីវឧស្ម័ន**

-ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន

-ផលិតឡជីវឧស្ម័នសរុបចំនួន ៨៣ឡ ។

## ៥ ផ្នែកកៅស៊ូ

### ៥.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០២-២០១១ (ហ.ត) | ផលិតផលអនុវត្តបានដល់ខែនេះ (តោន) | បញ្ចេញលក់ដល់ខែនេះ (តោន) |
|---|---|---|---|---|---|
| *I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ* | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៣៦៧,៧០ | ៣៧០,៧១ | ១៧៤,៩៧ | ៩៤,០០ |
| | *សរុប I* | *៣៦៧,៧០* | *៣៧០,៧១* | *១៧៤,៩៧* | *៩៤,០០* |
| *II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន* | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ៩.៣៥៦,៨៨ | ៦.៦៨៩,៤៤ | ៩.៤៤០,០៦ | ៦.៩៩៣,៨០ |
| ២ | ក្រុមហ៊ុន ស៊ីហ្វរ៉ាប់បើលីមីធីត(តេនគីរ) | ៨៦៧,៩៤ | ៩៥៤,៨៩ | ៦៤៥,៩៣ | ៥៤០.០០ |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៦៦,៨០ | ៨៨៥,០១ | ៤៨៦,៩០ | ៣៣២,០០ |
| ៤ | ក្រុមហ៊ុន ចម្ការកៅស៊ូបឹងកេត | ២.០៥៦,៣២ | ៣.២៦៦,៩២ | ១.៣៨០,៨៦ | ១.២២១,០០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៩៥,៥៨ | ៤.៤៩៦,៦៥ | ២.៣៣៤,២០ | ១.៦០០,០០ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វីសលស់(ស្នួល) | ១.៥៦១,៨០ | ២.៨២៤,៤១ | ១.៣៧៩,៦២ | ១.៣៣៤,៥០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប(ពាមជាំង) | ២.២៤៣,២៦ | ១.១៥៧,៦៥ | ៦៤៣,៧៣ | ៥៧៩,៤០ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប(ចម្ការអណ្តូង) | ២.១៣៥,២៩ | ៣.៦៨៧,៥៣ | ៧០៣,៨៧ | ៥៣៦,០០ |

| | | | | | |
|---|---|---|---|---|---|
| ៩ | ក្រុមហ៊ុន អានម៉ានីគ្រុប (មោសវែរក) | | ១.៩៧០,៦៣ | | |
| ១០ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ២.៨៩២,៧២ | ២.៦១៤,៩៥ | ១.៨៨៣,៧៦ | ១.៦៦១,៤០ |
| *សរុប II* | | *២៩.៦៣៦,៥៩* | *២៨.១៤៨,០៨* | *១៨.៨៩៨,៩៣* | *១៨.៧៩៨,១០* |
| សរុប I+II | | ២៦.០០៤,២៩ | ២៨.៥១៨,៧៩ | ១៩.០៧៣,៩០ | ១៨.៨៩២,១០ |

**៥.២ ការផ្សព្វផ្សាយនិងបណ្តុះបណ្តាល**

-ចុះទៅស្រង់ទិន្នន័យចម្ការពិសោធន៍នៅចម្ការកៅស៊ូក្រែក ខេមបូឌា ខេត្តកំពង់ចាម

-បន្តដឹកនាំសរសេរសារណាបទរបស់និស្សិតសាកលវិទ្យាល័យស្វាយរៀងចំនួន០២នាក់

-យកសំណាកស្លឹកកៅស៊ូចម្បារពូជកសិករក្នុងស្រុកចម្ការលើនិងច្បារពូជក្រុមហ៊ុនជុប ដើម្បីវិភាគ DNA។

**៥.៣ ការស្រាវជ្រាវអំពីការបង្កាត់ពូជ**

-ត្រួតពិនិត្យទូទៅការថែទាំឡូត៍ពិសោធន៍

-ចុះអង្កេតនិងស្រង់ទិន្នន័យដំណាក់កាលក្រប់ឡូត៍ពិសោធន៍កូន

-រៀបចំដាំច្បារបង្កាត់ពូជ(Hand Pollination Garden) លើផ្ទៃដីសរុបចំនួន២,៦៤ហិកតា។

**៥.៤ ការស្រាវជ្រាវអំពីសរីរវិទ្យានិងអាជីវកម្ម**

-ចំពោះប្រព័ន្ធចៀរជ័រ $S/_2$ d3 7d/7: ពូជ PB330 ទទួលទិន្នផល ៤០,៥ក្រាមក្នុងមួយដើមក្នុងមួយពន្លាកខ្ពស់ជាងពូជGT1 ពូជIRCA230 ពូជPB217 ពូជIRCA109 និងពូជRRIM600 នៅបច្ច័យ T1: ET 1,5% Pa1(1) $7/_y$

-ចំពោះប្រព័ន្ធចៀរជ័រ $S/_2$ d4 7d/7: ពូជ IRCA230 ទទួលទិន្នផល ៣២,៨ក្រាមក្នុងមួយដើមក្នុងមួយពន្លាកខ្ពស់ជាងពូជGT1 ពូជPB260 និងពូជRRIM712

-ប្រើប្រាស់ក្បាំងទឹកភ្លៀងបច្ច័យ T2(R) : ET 2.5% Pa1(1) $8/_y$ បានទទួលទិន្នផល ១៤,៥ក្រាមក្នុងមួយដើមក្នុងមួយពន្លាកខ្ពស់ជាងបច្ច័យ T0(R): Nil stimulation T1(R) : ET 1.5% Pa1(1) $5/_y$ និងT3 (R): ET 2.5% Pa1(1) $12/_y$ បានទទួលទិន្នផល ១២,១ក្រាម ១៤,៣ក្រាម និង១១,១ក្រាម។

**៥.៥ ការស្រាវជ្រាវ ការដាំដុះ និងការពារ**

-តាមដាននិងស្រង់ទិន្នន័យទិន្នផលចម្ការពិសោធន៍

-សហប្រតិបត្តិការជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Nagoya Kyushu and Hawaii ដើម្បីបំពាក់ឧបករណ៍ស្រាវជ្រាវអំពីវដ្តនៃទឹកភ្លៀងលើដំណាំកៅស៊ូ (Throw fall and stem flow) និងជួសជុល ថែទាំឧបករណ៍ Sap flow។

**៥.៦ ការងារនៅស្ថានីយអនុវត្ត**

-ដាំជួសនៅឡូត៍ 53ASW-53ASE (ដាំឆ្នាំ២០១២) បានចំនួន១.៣៧៨កូន ក្នុងនោះមានពូជPB217 ចំនួន៧៨៧កូន និងពូជIRCA230 ចំនួន៥៩១កូន

-ដាំកូនកៅស៊ូនៅឡូត៍ 53DNW ពូជRRIC100 បានចំនួន៣.៤០២កូន និងនៅឡូត៍43BNW ពូជHarbel60 ចំនួន៣.៦៩០កូន

-កាត់ស្មៅនៅក្នុងបរិវេណប្លុក ១២, ១១, ២១ និងកាត់ស្មៅតាមចន្លោះរងនៅឡូត៍ 52BSE

-ប្រមូលផលជ័រស្ងួតបានចំនួន៣២,៤០៥តោន។

**៥.៧ ការងារក្នុងមន្ទីរពិសោធន៍យថាប្រភេទ**

-ធ្វើតេស្តវិភាគសំណាកយថាប្រភេទចំនួន២១ភាគសំណាក ដើម្បីបញ្ជាក់គុណភាពការកែច្នៃរបស់រោងចក្រ

-សរុបលទ្ធផលបំពេញបន្ថែមឆ្លើយតបកែតម្រូវភាពមិនប្រក្រតីនៃការត្រួតពិនិត្យឡើងវិញពី BoA

-វិភាគលទ្ធផលធ្វើតេស្តសារធាតុហើរតាមបទដ្ឋាន ISO248-1:2011 ថ្មី

-ពន្យារសកម្មភាពឧបករណ៍ពិសោធន៍តាមបទដ្ឋាន

-ចុះបេសកកម្មជួយបណ្តុះបណ្តាលបុគ្គលិកមន្ទីរពិសោធន៍យថាប្រភេទតាមបណ្តាក្រុមហ៊ុនកែ្រក(ខេមបូឌា)ខូអិលធីឌី ស្តីពីនីតិវិធីធ្វើតេស្តនិងចេញវិញ្ញាបនបត្រយថាប្រភេទកៅស៊ូកម្ពុជា CSR និងវិធីត្រួតពិនិត្យការពន្យារសកម្មភាពឧបករណ៍មន្ទីរពិសោធន៍។

## ៦ ផ្នែករដ្ឋបាល

-ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា *ក្នុងខែចំនួន៤១៦ច្បាប់* សរុបចំនួន៣.០៦៣ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទ *ក្នុងខែចំនួន៣០៣ច្បាប់* សរុបចំនួន១.៩៦០ច្បាប់ និងទទួលពីរាជធានី ខេត្ត *ក្នុងខែចំនួន១០២ច្បាប់* សរុបចំនួន៥៣០ច្បាប់

-បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត *ក្នុងខែចំនួន៨២៩ច្បាប់* សរុបចំនួន៤.៩៨៥ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ *ក្នុងខែចំនួន៣១ច្បាប់* សរុបចំនួន៣១៧ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ *ក្នុងខែចំនួន១៤៩ច្បាប់* សរុបចំនួន៦២៨ច្បាប់

-ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិជាដើម ...។ល។

## ៧ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

-បើកសិក្ខាសាលាត្រួតពិនិត្យវាយតម្លៃវឌ្ឍនភាពពាក់កណ្តាលអាណត្តិនៃការអនុវត្តសកម្មភាពគម្រោង LWR-46 ស្តីពី Improved Irrigation water management to increase rice productivity in Cambodia មានអ្នកចូលរួមចំនួន២២នាក់

-បើកសិក្ខាសាលាស្តីពីការចាប់ផ្តើមដំណើរការគម្រោង Climate-Smart Agriculture for Poor Rural Communities in Cambodia ដែលមានអ្នកចូលរួមចំនួន២១រូប

-ចូលរួមកិច្ចប្រជុំតុមូលអាស៊ានបូក៣ លើកទី៥ ស្តីពីកសិកម្មនិងយុទ្ធសាស្រ្តនៃកិច្ចសហប្រតិបត្តិការដើម្បីសន្តិសុខស្បៀង ដែលប្រព្រឹត្តទៅនៅប្រទេសចិន

-ដឹកនាំក្រុមការងារចុះជួយរៀបចំទស្សនកិច្ចសម្រាប់គណៈប្រតិភូកិច្ចលនៃព្រះរាជាណាចក្រកម្ពុជា នៅរោងម៉ាស៊ីនកិនស្រូវរបស់ក្រុមហ៊ុន អង្គរកសិកម្មរុងរឿង នៅស្រុកអង្គស្នួល ខេត្តកណ្តាល

-ទទួលដំណើរទស្សនកិច្ចក្រុមហ៊ុនមកពីប្រទេសកូរ៉េនិងពិភាក្សាការងារស្តីពី Status of Research and Prospect in CARDI and other Information about Agro & Fisheries Products Export Status in Cambodia ដែលមានអ្នកចូលរួមសរុប១៤រូប

-បន្តការងារពិសោធន៍ស្រាវជ្រាវនៅក្នុងវិទ្យាស្ថាននិងតាមរាជធានី ខេត្ត

-ចុះពិនិត្យស្ថានភាពទូទៅនៃតំបន់ផ្ទេរងទឹកភ្លៀងព្រែកត្នោតជាមួយក្រុមការងារអភិវឌ្ឍន៍គម្រោងSLM របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខេត្តកំពង់ស្ពឺ

-ចុះកំណត់សមាសភាពចង្រៃលើដំណាំសណ្តែកសៀងនៅខេត្តកំពង់ចាម

-ចុះត្រួតពិនិត្យការដកនិងស្ទូងពិសោធន៍ពូជ និងពិសោធន៍ជីនៅតំបន់ដីប្រៃនៅខេត្តកោះកុង

-ចុះបាចជីពិសោធន៍ វាស់ទឹកក្រោមដី និងចែកពូជស្រូវពិសោធន៍នៅខេត្តតាកែវ ខេត្តកំពត និងខេត្តព្រៃវែង

-បន្តបញ្ចូលទិន្នន័យនិងសរសេររបាយការណ៍ស្រាវជ្រាវប្រចាំឆ្នាំ២០១៣។

## ៨ ផ្នែកការងារបញ្ជ្រាបយេនឌ័រ

-ចូលរួមសិក្ខាសាលាស្តីពីការកែលម្អជីវភាពរស់នៅរបស់ស្ត្រីជនបទនៃគម្រោងបញ្ជ្រាបយេនឌ័រដំណាក់កាលទី២ (PGM2) នៅសណ្ឋាគារភ្នំពេញ

-ចូលរួមសិក្ខាសាលាស្តីពីការផ្តល់អនុសាសន៍សំខាន់ៗលើគោលនយោបាយទាក់ទងនឹងការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីសម្រាប់ថ្នាក់ខេត្ត (ផែនការអភិវឌ្ឍន៍ខេត្ត) និងផែនការអភិវឌ្ឍន៍ថ្នាក់ជាតិ នៅសណ្ឋាគារ ហ៊ីម៉ាវ៉ារី

-ក្រៅពីនេះ ការបញ្ចូលសកម្មភាពយេនឌ័រទៅតាមគម្រោងនានាក៏ដូចជាការបញ្ជូនមន្ត្រីនារីទៅចូលរួមវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលាផ្សេងៗទាំងនៅក្នុងនិងក្រៅប្រទេសក៏ត្រូវបានយកចិត្តទុកដាក់ផងដែរ។

## ៩ ផ្នែកការងារសមាគមមិត្តបុគ្គលិកកសិកម្មកម្ពុជា

-តាមរបាយការណ៍ពីសមាគមមិត្តបុគ្គលិកកសិកម្មកម្ពុជា(ស.ប.ក) បានបង្ហាញថា សមាគមមិត្តបុគ្គលិកកសិកម្មកម្ពុជាចំនួន៤២សាខា ដោយមានមន្ត្រីរាជការនិងនិវត្តជននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចូលជាសមាជិកចំនួន ៦.៣៤២នាក់ ក្នុងនោះសមាជិកចូលថ្មីចំនួន០១នាក់ និងលុបឈ្មោះចេញចំនួន០៤នាក់

-សមាជិកចំនួន០៣នាក់ និងគ្រួសារសមាជិកចំនួន០៣នាក់ បានទទួលមរណភាព ក្នុងនោះសមាគមមិត្តបុគ្គលិកកសិកម្មកម្ពុជាបានឧបត្ថម្ភនូវថវិកាដល់សពសរុបចំនួន ២៨.០៨៣.០០០រៀល។ ដោយឡែក ឯកឧត្តមបណ្ឌិត ចាន់ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានគណៈកម្មាធិការសមាគមមិត្តបុគ្គលិកកសិកម្មកម្ពុជានិងលោកជំទាវ បានឧបត្ថម្ភនូវអង្ករដល់សពសមាជិកម្នាក់ៗចំនួន១០០គីឡូក្រាម សរុបចំនួន៣០០គីឡូក្រាម។

## ១០ សាលាជាតិកសិកម្មព្រែកលៀប

### ១០.១ និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១២-២០១៣ សរុបមានចំនួន១.៥៧២នាក់(ស្រី៥១៣នាក់)ក្នុងនោះ÷

•និស្សិតអាហារូបករណ៍ចំនួន១.២០៥នាក់ ក្នុងនោះស្រី៤៣៨នាក់ ÷

-ថ្នាក់បរិញ្ញា *៩៦២*នាក់ (ស្រី ៣៤៧នាក់ ) សិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិឧស្សាហកម្ម និងស៊ីវិលយោធី

-ថ្នាក់បរិញ្ញារង *២៤៣*នាក់ (ស្រី ៩១នាក់) សិក្សាលើមុខជំនាញក្សេត្រសាស្ត្រ រុក្ខកម្ម ផលិតកម្មនិងបសុព្យាបាល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម ជលផល កសិឧស្សាហកម្ម និងស៊ីវិលយោធី។

•និស្សិតបង់ថ្លៃចំនួន១៩៦នាក់ ក្នុងនោះស្រី២៧នាក់ ÷

-ថ្នាក់បរិញ្ញា *១៥៤*នាក់ (ស្រី ២៤នាក់ ) សិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម កសិឧស្សាហកម្ម និងស៊ីវិលយោធី

-ថ្នាក់បរិញ្ញារង *៤២*នាក់ (ស្រី ០៣នាក់) សិក្សាលើមុខជំនាញក្សេត្រសាស្ត្រ រុក្ខកម្ម ផលិតកម្មនិងបសុព្យាបាល និងផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ។

•និស្សិតបណ្តុះបណ្តាលបន្តថ្ងៃសៅរ៍-អាទិត្យចំនួន១៧១នាក់ ក្នុងនោះ ស្រី៤៨នាក់ ÷

-ថ្នាក់បរិញ្ញា *១៣៩*នាក់ (ស្រី ៤២នាក់) សិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ និងស៊ីវិលយោធី

-ថ្នាក់បរិញ្ញារង *៣២*នាក់ (ស្រី ០៦នាក់) សិក្សាលើមុខជំនាញផលិតកម្មនិងបសុព្យាបាល ។

**១០.២ ការងារផលិតកម្មនិងស្រាវជ្រាវ**

-កសិដ្ឋានដំណាំលម្អបានដាំផ្កា ឈើពណ៌ ដូងតាំង និងពង្រីកពូជបន្ថែមសម្រាប់ការអនុវត្តនិងដាំលម្អក្នុងបរិវេណសាលាជាតិ បណ្តុះកូនក្លាន ល្អិតទុយកំប្រុក។

## ១១ សាលាជាតិកសិកម្មកំពង់ចាម

**១១.១ និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១២-២០១៣ សរុបមានចំនួន១.៥៥៩នាក់(ស្រី៦០៨នាក់) ក្នុងនោះ ÷**

-និស្សិតអាហារូបករណ៍សរុប១.២៩៥នាក់(ស្រី៥៣៥នាក់)ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៩១៣នាក់(ស្រី៣៣៩នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម៣៨២នាក់(ស្រី១៩៦នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

-និស្សិតសិក្សាបង់ថ្លៃ២៦៤នាក់ (ស្រី៧៣នាក់) ថ្នាក់បរិញ្ញាចំនួន២៥២នាក់(ស្រី៧៣នាក់) និងថ្នាក់បរិញ្ញារងចំនួន១២នាក់(ស្រី០នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ ។

**១១.២ ការងារពិសោធន៍ស្រាវជ្រាវ**

-ធ្វើការពិសោធន៍ដំណាំសណ្តែកសៀង

-ធ្វើការពិសោធន៍លើប្រសិទ្ធភាពជីអាសូត ផូស្វរ ប៉ូតាស្យូម លើការលូតលាស់ដំណាំម្ទេសដៃនាង

-ពិសោធន៍តាមដានការលូតលាស់ជ្រូកមេក្នុងការចិញ្ចឹមតាមរយៈការប្រើប្រាស់ចំណីឧស្សាហកម្ម។

**១១.៣ ការងារស្រាវជ្រាវ ផ្សព្វផ្សាយ និងការផ្ទេរបច្ចេកវិទ្យាកសិកម្ម**

-លើកគម្រោងចំនួន១១ស្នើសុំថវិកាសម្រាប់ធ្វើការស្រាវជ្រាវលើប្រធានបទស្តីពីការពិសោធន៍កសិកម្ម វារីវប្បកម្ម បសុវប្បកម្ម និងសង្គមជនបទ

-បន្តការងារស្រាវជ្រាវផលិតកម្មដំណាំស្រូវ ដែលបានឧបត្ថម្ភជំនួយពី ACIAR-CARF

-បន្តការងារស្រាវជ្រាវលើបសុវប្បកម្ម ដែលបានឧបត្ថម្ភជំនួយពី DEL-phe(UK)

-ផ្សព្វផ្សាយពីការធ្វើឥណទានស្រូវពូជ ជ្រូកពូជ និងចាក់វ៉ាក់សាំងការពារជំងឺសត្វគោ-ក្របី នៅតាមមូលដ្ឋានឃុំ-ស្រុក ក្នុងខេត្តកំពង់ចាម

-ផ្តល់ជ្រូកពូជជូនដល់កសិករក្រីក្រនៅស្រុកត្រាំកក់ខេត្តតាកែវនិងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាមបានចំនួន១៨គ្រួសារ

-ធ្វើការប្រជុំកសិករណែនាំពីការប្រើប្រាស់ថ្នាំពុលគីមី ជីគីមី និងជីសរីរាង្គ នៅក្នុងមូលដ្ឋានស្រុកត្រាំកក់ ខេត្តតាកែវ និងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

## ១២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

-និស្សិតដែលកំពុងសិក្សាមានចំនួនសរុប៥.៦៥៧នាក់ (ស្រី១.២៣៣នាក់) ចែកចេញជា១០មហាវិទ្យាល័យគឺ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ កសិឧស្សាហកម្ម រៀបចំដែនដីនិងរដ្ឋបាលដីធ្លី វិទ្យាសាស្ត្រកៅស៊ូ ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាវិទ្យាសាស្ត្រនិងសាលាក្រោយឧត្តម បណ្តុះបណ្តាលលើកម្មវិធីបរិញ្ញារង បរិញ្ញាបត្រ បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិតវិទ្យាសាស្ត្រ

-បើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន២៥លើក និងក្រៅប្រទេសចំនួន២១លើក និងសិក្ខាសាលាក្នុងប្រទេសចំនួន២៤លើក និងក្រៅប្រទេសចំនួន២២លើក

-បញ្ជូននិស្សិតទៅចូលរួមវគ្គបណ្តុះបណ្តាលនិងកម្មសិក្សានៅក្រៅប្រទេសចំនួន១២នាក់ និងមន្ត្រីរាជការចំនួន១២នាក់

-បញ្ជូននិស្សិតទៅធ្វើកម្មសិក្សានៅប្រទេសអ៊ីស្រាអែលចំនួន៣០នាក់

-អនុវត្តគម្រោងស្រាវជ្រាវនិងអភិវឌ្ឍន៍ចំនួន២៣គម្រោង គម្រោងទាំងនោះមានគម្រោងស្រាវជ្រាវនិងអភិវឌ្ឍន៍ចម្រុះជំនាញផ្នែកវិទ្យាសាស្ត្រកសិកម្ម ផ្នែកវិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ ផ្នែកវិទ្យាសាស្ត្រព្រៃឈើ ផ្នែកវិទ្យាសាស្ត្រជលផល ផ្នែកស្រាវជ្រាវ-ផ្សព្វផ្សាយ ផ្នែករៀបចំដែនដីនិងរដ្ឋបាលដីធ្លី

-ធ្វើការផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមករវាងសាស្ត្រាចារ្យនិងនិស្សិត ព្រមទាំងខិតខំពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិយ៉ាងទូលំទូលាយ ក្នុងទិសដៅពង្រឹងគុណភាពអប់រំឱ្យបានល្អប្រសើរដើម្បីឱ្យមានលក្ខណៈប្រកួតប្រជែង

-បញ្ជូននិស្សិតចុះជួយវាស់វែងដីធ្លីជូនប្រជាជន ដើម្បីចូលរួមអនុវត្តនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លីរបស់រាជរដ្ឋាភិបាលចំនួន៤២៩នាក់ មកពីមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី វិទ្យាសាស្ត្រកសិកម្ម និងសេដ្ឋកិច្ចកសិកម្មនិងជនបទ។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ជារួមការងារបង្កបង្កើនផលស្រូវនៅដើមរដូវវស្សាឆ្នាំ២០១៣នេះ ស្ថានភាពទឹកភ្លៀងនៅមិនទាន់ច្រើន និងមិនទាន់រាយប៉ាយគ្រប់ទីកន្លែងនៅឡើយ តែដំណើរការការងារបង្កបង្កើនផលស្រូវរដូវវស្សាមានល្បឿនលឿនជាងឆ្នាំមុនបន្តិចបើប្រៀបធៀបរយៈពេលដូចគ្នា។ ប្រជាកសិករកំពុងខិតខំជំរុញការរៀបចំដី ភ្ជួររាស់ សាប-ព្រោះ និងដក-ស្ទូង ដើម្បីឱ្យទាន់រដូវកាលដាំដុះ។

## IV- ទិសដៅ

-ជំរុញការងារបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០១៣ ជាពិសេសស្រូវស្រាលដើមរដូវ

-ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០១ និង ០២

-បន្តជំរុញកំណត់ព្រំប្រទល់ដែនព្រៃឈើ ធ្វើចំណាត់ថ្នាក់ និងចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពពីគ្រប់ភាគីពាក់ព័ន្ធ ហើយត្រូវសម្រេចឱ្យបានប្រវែង១.០០០គីឡូម៉ែត្រ

-ជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការនិងតាមការពិន័យអន្តរការណ៍

-បន្តតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រសិទ្ធភាពនៃកម្មវិធី ដោយលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ និងការពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីចំនួន ១០០កន្លែងបន្ថែមទៀត

-បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ

-បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការអប់រំផ្សព្វផ្សាយពីសារប្រយោជន៍ស្តីពីព្រៃឈើ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេស

-បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើសត្វព្រៃតាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពស្រាវជ្រាវ

-កំណត់តំបន់ព្រៃឈើរេចរឹលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

-បន្តចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចុះដេញថ្លៃផល អនុផលព្រៃឈើដែលរឹបអូសដោយសាលក្រម ដីកាសម្រេច ពិន័យអន្តរការណ៍ និងឈើអញ្ញាតជន(ឈើគ្មានម្ចាស់)នៅទូទាំងប្រទេស

-បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារ

ព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់

-រៀបចំសេចក្តីណែនាំនិងដាក់ឱ្យប្រើប្រាស់សៀវភៅកត់ត្រាឈើចេញចូលតាមរោងសិប្បកម្មកែច្នៃ អនុផលព្រៃឈើ

-បន្តត្រួតពិនិត្យបទល្មើសនេសាទទឹកសាបក្នុងរដូវបិទនេសាទនៅរាជធានី ខេត្តឱ្យកាន់តែមានប្រសិទ្ធភាព

-បន្តការតាមដានសកម្មភាពអាជីវកម្មនេសាទសមុទ្រ

-បន្តការងារផ្សព្វផ្សាយការអភិវឌ្ឍវិស័យវារីវប្បកម្មនិងការគ្រប់គ្រងធនធានជលផល

-បន្តការងារស្រាវជ្រាវដើម្បីកំណត់អត្តសញ្ញាណកូនត្រីទៅតាមប្រភេទនីមួយៗនៅតាមដងទន្លេមេគង្គ

-រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត

-ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សី និងជំងឺផ្តាសាយ (A) H1N1

-ពង្រឹងទប់ស្កាត់ចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

-ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

-ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត

-ចូលរួមធ្វើតេស្តអន្តរមន្ទីរពិសោធន៍លើកទី ១០៥ ជាមួយ IRA

-អង្កេតទូទៅស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូនិងត្រួតពិនិត្យជំងឺកៅស៊ូ

-ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

-ពង្រឹងការងារបញ្ជិកាគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មរាជធានី ខេត្ត

-បន្តចុះពិនិត្យផ្ទាល់ដល់ទីវាលរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់

-បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវនិងកសាងគោលការណ៍លិខិតបទដ្ឋានណែនាំជាសារាចរ សេចក្តីណែនាំអំពីការងារគ្រប់គ្រងមន្ត្រីរាជការ និងរៀបចំបែបបទការអនុវត្តជាក់ស្តែងក្នុងការគ្រប់គ្រងធនធានមនុស្សឱ្យល្អប្រសើរតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ដោយចងក្រងតាមកម្រិតសញ្ញាបត្រ មុខជំនាញ និងតាមមុខតំណែង

-ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សឱ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា

-ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិក្នុងវិស័យកសិកម្មឱ្យបានទូលំទូលាយជាមួយគ្រប់ដៃគូពាក់ព័ន្ធទាំងអស់

-បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីព្រៃឈើ ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពពេញលេញក្នុងការអនុវត្ត

-បន្តរៀបចំច្បាប់លិខិតបទដ្ឋានគតិយុត្ត និងអត្ថបទក្រោមច្បាប់តាមអនុវិស័យ ដើម្បីដំណើរការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទឱ្យបានសមស្រប៕

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០១៣

**រដ្ឋមន្ត្រី**

**ចាន់ សារុន**